**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការក្រុងព្រះសីហនុ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១២៣ ចុះថ្ងៃទី ២៧

ខែ មិថុនា ឆ្នាំ ២០០៤

សាលក្រម

លេខៈ ១០៦ ចុះថ្ងៃទី ០១

ខែ ធ្នូ ឆ្នាំ ២០០៤

សាលក្រមនេះបានចូលជាស្ថាពរហើយ ។
ក្រុងព្រះសីហនុ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៤
ក្រឡាបញ្ជី [redacted]

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការ ជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅនេះ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញាស្តីទីអមតុលាការក្រុងព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**មេធាវីការពារជនជាប់ចោទ**

លោក [redacted] **សខ** ( អវត្តមាន )

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២៣ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទឈ្មោះ :

-**ចា បចា** ហៅក្រៅ **ស៊ីន** ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិភ្នំស្រុក ឃុំភ្នំស្រុក ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិវាលស្បូវ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល របររកស៊ីកម្មករធ្វើដបទឹកសុទ្ធ ឪពុកឈ្មោះ **ខ ត** ( រ ) ម្តាយឈ្មោះ **ខ សចណ** ( រ ) ប្រពន្ធឈ្មោះ **ឌ សរ** មានកូន ០២នាក់ ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៤ ។

ត្រូវជាប់ចោទពីបទបៀតបៀនដល់កេរ្តិ៍ខ្មាស់ ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-កុមារីឈ្មោះ **ឧ ចច** អាយុ ០៨ឆ្នាំ ជាតិខ្មែរ របររកស៊ី កូនសិស្ស មានទីលំនៅក្រុម ១៣ ភូមិ ៣ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ជាជនរងគ្រោះ ។

-ឈ្មោះ **ចា សច** ភេទស្រី អាយុ ៤៧ឆ្នាំ របររកស៊ី កម្មករស្ថានីយ៍ប្រេងឥន្ធនៈ ប៉ៃត្រូណាស់ មានទីលំនៅក្រុមទី ១៣ ភូមិ ៣ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ជាដើមបណ្តឹងរដ្ឋប្បវេណី ។

CamScanner

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៤៣៩ ដសព ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១២៣៧ ត.ព ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១២៣០ ត.ព ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

## **អង្គហេតុមានដូចតទៅ :**

កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៤ វេលាម៉ោង ១២យប់ ឈ្មោះ **ម មម** បានចូលទៅក្នុងផ្ទះរបស់ឈ្មោះ **ម សធ** ហើយបានបីឈ្មោះ **ឆ ឆទ** ទៅបន្ទប់ទឹក រួចក៏ស្រាតខោកុមារី រួចក៏ពោបពីលើកុមារី រួចក៏ម៉េបដើរចេញ ឯកុមារីក៏ទៅប្រាប់ម្តាយខ្លួន និង ឪពុកខ្លួន ក៏តាមចាប់ **ម មម** ទាំងយប់ លុះព្រឹកឡើងក៏ចាប់ខ្លួនឈ្មោះ **ម មម** តែម្តងទៅ ។

## **នាពេលសវនាការ**

-ឈ្មោះ **ម មម** ជាជនជាប់ចោទបានឆ្លើយថា ខ្លួនកន្លងមករស់នៅក្រុងព្រះសីហនុ ហើយខ្លួនស្គាល់ក្រុមគ្រួសារឪពុកម្តាយរបស់ **ឆ ឆទ** ផងដែរ ក្នុងរយៈពេលតែ ០៤ ទៅ ០៥ខែប៉ុណ្ណោះ ។ ក្នុងកំឡុងឆ្នាំ ២០០០ ខ្លួនក៏ឈប់ធ្វើការនៅកំពង់ផែ ហើយទៅរស់នៅក្រុងភ្នំពេញ ក៏មានគ្រួសារមួយទៀត នៅភូមិវាលស្បូវនោះ រំលងបានជាយូរខែ ខ្លួនក៏មកលេងជាមួយកូនខ្លួន ដែលរស់នៅជាមួយម្តាយដើមនៅឯក្រុងព្រះសីហនុ នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៤ ខ្លួនមកលេងក្រុងព្រះសីហនុ ក្នុងគោលបំណងមកលេងនឹងកូន ពេលមកដល់ខ្លួនមិនបានទៅដល់ផ្ទះកូនខ្លួនទេ គឺខ្លួនទៅសំរាកនៅម្តុំវ៉ាមួយយប់ គឺសំរាកនៅផ្ទះធ្លាប់ស្គាល់គ្នា លុះព្រឹកឡើងថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ ខ្លួនក៏បានធ្វើដំណើរទៅ CT ទៅលេងនឹងកូនរហូតដល់ម៉ោង ៦-៧ ល្ងាច ខ្លួនក៏បានទៅផ្ទះ **ម សធ** ដែលផ្ទះគាត់ស្ថិតនៅក្នុងហ្គារាសសាំង Pettronas ពេលនោះគាត់មិននៅផ្ទះការដែលខ្លួនទៅលេង **ម សធ** នេះ គឺឈ្មោះ **តត្តិ** បានអោយខ្លួនទៅខ្ចីប្រាក់ពីគាត់ ហើយពេលនោះមិនជួបគាត់ គឺជួបតែកូនប៉ុណ្ណោះ ហើយខ្លួនក៏ត្រឡប់មកផ្ទះវិញ ពេលខ្លួនត្រឡប់មកវិញ ខ្លួនទៅមើលកន្លែងគេលេងអាប៉ោង ហើយមិនឃើញគាត់ក៏បែកគ្នាជាមួយឈ្មោះ **តត្តិ** ទៅ ហើយខ្លួនក៏ឡើងជិះម៉ូតូទៅសូរិយាប្រហែលជាម៉ោង ០៩យប់ ខ្លួនក៏មកជាមួយពួកម៉ាកខ្លួនឈ្មោះ **អ ត ឈ** ខ្លួនក៏បានស្នាក់នៅផ្ទះអ៊ុំម្នាក់ដែលស្គាល់គ្នាដែលនៅជិតផ្ទះប្រពន្ធដើមខ្លួន ក្នុងយប់នោះប្រហែលជាម៉ោង ២-៣រំលងអាធ្រាត ស្រាប់តែឮសូរគេស្រែកហៅខ្លួន ខ្លួនក្រោកឡើងបើកទ្វារ ស្រាប់តែឃើញមានមនុស្សយ៉ាងច្រើនប្រហែលជា ៧-៨នាក់ ក្នុងនោះមានឈ្មោះ **ដារិទ្ធ** នៅទីនោះដែរ ដោយគាត់មិនបានសួរនាំអ្វីឡើយ គាត់ក៏បានទាញកអាវខ្លួន ហើយមិនដឹងពីណាវាយខ្លួនទៀត ខ្លួនក៏ស្ទុះរត់ចេញដើម្បីកុំអោយគេវាយធ្វើបាបក្នុងយប់នោះ លុះព្រឹកឡើងខ្លួនក៏ទៅផ្ទះប្រពន្ធខ្លួនដើម្បីសួររកហេតុផល ថាយប់មិញនរណាវាយធ្វើបាបខ្លួន ហើយគេប្រាប់ថា អោយខ្លួនរត់ទៅ ខ្លួនក៏ឡើងមកផ្លូវទៅហៅម៉ូតូឌុបជិះសំដៅទៅឃ្លាំងលើដើម្បីទៅវាលរេញ ពេលជិះដល់ចំណតឃ្លាំងលើមានគេកំពុងជួសជុលផ្លូវឡានកំពុងតែបន្ថយល្បឿនពេលនោះស្រាប់ឃើញប្តីរបស់ឈ្មោះ **ម សធ** ជិះម៉ូតូមួយគ្នាពីរនាក់ ហើយហៅឡានអោយឈប់ រួចស្រែកថា ចោរ១ជួយចាប់ចោរ ខ្លួនក៏ចុះពីលើរថយន្តស្រាប់តែឈ្មោះ **ដារិទ្ធ** និង ម្នាក់ទៀតដែលខ្លួនមិនស្គាល់បានវាយខ្លួនជាច្រើនដៃទាត់ជាច្រើនជើង ហើយគាត់អោយម៉ូតូឌុបទៅហៅ PM នៅចំការកៅស៊ូ ក៏ឃើញ PM មកយកខ្លួនទៅស្នាក់ការសួរ

ព្រមទាំងធ្វើកំណត់ហេតុ ។

ចំពោះបញ្ហានេះ ខ្លួនមិនបានប្រព្រឹត្តដូចតំណាងអយ្យការបានចោទប្រកាន់នោះទេ ហេតុដូច្នេះសូមអោយតុលាការរកយុត្តិធម៌អោយខ្លួនផង ។

-ឈ្មោះ **ឆ ឆទ** ជាជនរងគ្រោះបានឆ្លើយថា ខ្លួនរស់នៅជាមួយឪពុកម្តាយ ហើយរាល់យប់ពេលសំរាកផ្ទះក្នុងមិនដែលបិទទ្វារទេ ព្រោះផ្ទះនោះ គឺបង្អួចកញ្ចក់ ទ្វារកញ្ចក់ ដូច្នេះរាល់យប់ក្តៅជាហេតុធ្វើអោយឪពុកម្តាយខ្លួនសំរាន្តបើកទ្វារហូត គឺផ្ទះរបស់ហ្គារាសសាំង ។

-ក្នុងយប់កើតហេតុនោះ ខ្លួនដេកជាមួយម្តាយ និង បងរហូតដល់ម៉ោង ១២យប់ ពេលនោះខ្លួនដឹងខ្លួនស្រាប់តែនៅក្នុងបន្ទប់ទឹកដោយឈ្មោះ **ច្វរ** កំពុងតែបីខ្លួន ហើយខ្លួនបានស្គាល់ច្បាស់តាមរយៈខែភ្លឺ ហើយខ្លួនក៏បានប្រាប់អោយគាត់ដាក់ខ្លួនចុះ ហើយគាត់ប្រាប់ថា បើហ៊ានស្រែកគាត់នឹងច្របាច់កអោយងាប់ ខ្លួនភ័យក៏មិនហ៊ានស្រែកគាត់ក៏ដាក់ខ្លួនចុះ ហើយគាត់ក៏បានស្រាតខោអាវរបស់ខ្លួន ខោខ្លីគាត់មិនបានស្រាតទេ ហើយគាត់ក៏បានពោបពីលើខ្លួនខ្លួនក៏គេចចេញ ហើយឃើញដៃគាត់លូកក្នុងខោរបស់គាត់ ស្រាប់តែគាត់ងើបចេញពីខ្លួន ហើយខ្លួនក្រោកឡើងរត់ទៅប្រាប់ម្តាយ ហើយក៏ផ្អើលឆោឡោក្នុងយប់នោះ លុះព្រឹកឡើងទើបដឹងថា សមត្ថកិច្ចចាប់ខ្លួនបានឈ្មោះ **ឃ មឃ** ។

-ឈ្មោះ **ឃ សឆ** ជាដើមបណ្តឹងបានឆ្លើយថា **ឆ ឆទ** ជាកូនបង្កើតរបស់ខ្លួន ហើយកន្លងមកស្គាល់ឈ្មោះ **ឃ មឃ** ដែលពីមុនមកធ្លាប់ធ្វើការនៅកំពង់ផែជាមួយប្តីខ្លួនដែរ ហើយគាត់ជួលផ្ទះនៅជិតខ្លួនដែរ ក្រោយមកគាត់ក៏ឈប់ធ្វើការពីកំពង់ផែ ក៏បាត់គាត់រហូត ស្រាប់តែឮដំណឹងថា គាត់លក់ឈ្មោះដែលគាត់ធ្វើការនៅកំពង់ផែអោយទៅអ្នកដទៃបាត់ទៅ ។ ស្រាប់តែនៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ វេលាម៉ោងប្រហែល ០៥ ទៅ ០៦ ល្ងាច ស្រាប់តែឃើញ **ឃ មឃ** មកលេងផ្ទះខ្លួន ពេលខ្លួនត្រៀមចេញដំណើរទៅមុជទឹក ។ នៅយប់នោះកូន និង ប្តីខ្លួនមកពីមើលវីដេអូប្រហែលជាម៉ោង ១០យប់ ទើបចូលផ្ទះ ខ្លួនសុំបញ្ជាក់ថា ផ្ទះខ្លួនសំរាកមានបង្អួចធ្វើពីកញ្ចក់ និង ទ្វារធ្វើពីកញ្ចក់ដែរដោយក្តៅពេក គឺរាល់យប់ដេកបើកទ្វារ ប្តីខ្លួនគាត់សំរាន្តនៅក្បែរមាត់ទ្វារខ្លួន និង កូនសំរាន្តនៅជិតជញ្ជាំងខ្លួនកំពុងតែសំរាន្តលង់លក់ ស្រាប់តែឮសំលេងកូនខ្លួនឈ្មោះ **ឆ ឆទ** វាយំ ខ្លួន និង ប្តីក៏ភ្ញាក់ឡើងក៏សួរនាំវាទៅ វាក៏ប្រាប់ថាឈ្មោះ ពូ **ច្វរ** ចាប់វាយកទៅបន្ទប់ទឹក ហើយស្រាតខោវា ហើយឈ្មោះ **ច្វរ** បានដេកពោបលើវា កូនខ្លួនក៏លើកខោឡើងឈ្មោះ **ច្វរ** ក៏ងើបឡើងរត់ចេញពីបន្ទប់ទឹក ពេលយប់នោះក៏មានផ្អើលឆោឡោឡើង ខ្លួនក៏ទៅប្តឹងប៉ូលីសនៅសង្កាត់លេខ ២ អោយជួយអន្តរាគមន៍ ។ ប្តីខ្លួននាំគ្នាតាមរកឈ្មោះ **ច្វរ** ទាំងយប់ លុះព្រឹកឡើងប្តីខ្លួនតាមឃ្លាំមើលទៀត ក៏បានជួបឈ្មោះ **ឃ មឃ** នៅឃ្លាំងលើជិតស្រាបៀរអង្គរ កំពុងតែជិះឡានតាក់ស៊ីវាលវេញ ពេលចាប់បានប្តីខ្លួនក៏បានទះពីរបីដៃ ដោយសារខឹងខ្លាំងពេក ។ ក្នុងរឿងនេះខ្លួនមិនទាមទារសំណងជម្ងឺចិត្តអ្វីទេ តែសុំអោយតុលាការផ្តន្ទាទោស តាមច្បាប់ចំពោះជនល្មើស ។

-ឈ្មោះ **ម ជរ** ជាសាក្សីបានឆ្លើយថា នៅយប់កើតហេតុខ្លួនកំពុងតែសំរាន្តនៅក្បែរមាត់ទ្វារ ហើយមិនមានបិទមាត់ទ្វារទេ ប្រហែលម៉ោង ១២យប់ស្រាប់តែឮសំលេងកូនខ្លួនយំ ដល់សួរវាទៅវាប្រាប់ថាឈ្មោះ **ច្វរ** បីវាទៅបន្ទប់ទឹក ឮដូច្នេះខ្លួនក៏យកពិលដើររកមើលខាងក្រោយហ្គារាសសាំង ដែលខ្លួនដេកយាមជារៀងរាល់យប់ តែកូនខ្លួនប្រាប់ថា ឈ្មោះ **ច្វរ** ឡើងតាមរបងទៅបាត់ហើយ ខ្លួនក៏បានអោយប្រពន្ធខ្លួននាំកូនពិនិត្យប្រដាប់ភេទរបស់វា តើមានគេរំលោភដែរឬទេ បន្ទាប់មកប្រពន្ធខ្លួនប្រាប់ថា ពុំមានអ្វីគួរអោយកត់សំគាល់ទេ ។ ខ្លួនក៏អោយប្រពន្ធទៅប្តឹងសមត្ថកិច្ចនៅសង្កាត់ ២ ចំណែកខ្លួននៅមើលកូនក្រែងវាមកម្តងទៀត ក្នុងយប់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ នោះខ្លួនក៏តាមរកមើលឈ្មោះ **ឃ មឃ** ទៀត គឺទៅផ្ទះឈ្មោះ **ច្វរ** ស្នាក់នៅ ពេលទៅដល់ឈ្មោះ **ច្វរ** ក៏បើកមុងរុញច្រានមកលើខ្លួន ហើយរត់តែម្តង លុះព្រឹកឡើងក៏តាមឈ្មោះ **ច្វរ** ទៀត ក៏បានជួបឈ្មោះ **ច្វរ** ជិះម៉ូតូឌុបដល់កន្លែងតូប

យាយម៉ៅឈ្មោះ ហូះ ក៏រត់ឡើងជិះឡានវាលរេញ្ចៀវិញនៅម្តុំតូបយាយម៉ៅឃ្លាំងលើនោះ ក៏តាមទាន់នៅមុខហ្គារាសសាំងប៉េត្រូណាស់ឃ្លាំងលើ ក៏ចាប់ខ្លួនឈ្មោះ ចេ បចេ បានក៏បញ្ជូនទៅសមត្ថកិច្ច PM នៅទីនោះទៅ ។ មុនបញ្ជូនទៅសមត្ថកិច្ចនោះ ខ្លួនខឹងពេកក៏ទះជនល្មើសចំនួនមួយទៅពីរដៃទៅ ។ battery?

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ចេ បចេ ពីបទរៀតរៀងដល់កេរ្តិ៍ខ្មាស់ ប្រព្រឹត្តនៅសង្កាត់២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ តែក្នុងពេលសវនាការនេះ ជនជាប់ចោទឆ្លើយបដិសេធមិនទទួលស្គាល់កំហុសរបស់ខ្លួន តែជនរងគ្រោះគេស្គាល់មុខជនល្មើសច្បាស់តាមរយៈខែភ្លឺ ហើយនៅម្តុំនោះគ្មាននរណាឈ្មោះ ចេ បចេ ដែរ ហេតុនេះសុំអោយតុលាការជំនុំជំរះតាមមាត្រា ៤២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទបានឆ្លើយសំដីចុងក្រោយបង្អស់ និង ឆ្លើយការពារខ្លួនថា ខ្លួនគ្មានបានប្រព្រឹត្តអំពើដូចតំណាងអយ្យការធ្វើការចោទប្រកាន់នោះទេ ។ ហេតុនេះសុំអោយតុលាការជួយរកយុត្តិធម៌អោយខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹង

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

## តុលាការខេត្តព្រះសីហនុ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-តាមចម្លើយជនជាប់ចោទបានបញ្ជាក់ថា នៅយប់កើតហេតុនោះ គឺខ្លួននៅផ្ទះអ៊ុំម្នាក់ ដែលខ្លួនធ្លាប់ស្គាល់ហើយសំរាកនៅទីនោះ ក្នុងយប់នោះ គឺខ្លួនមិនចេញទៅណាទេនៅសំរាករហូតដល់ពេលគេទៅរករឿងខ្លួននៅឯផ្ទះអ៊ុំនោះ ដោយសារមានគេទៅច្រើនគ្នា និង គេវាយខ្លួនទៀត ទើបខ្លួនរត់ចេញពីផ្ទះអ៊ុំនោះទាំងយប់ ។

-តាមការអះអាងរបស់ឈ្មោះ ចេ បចេ បញ្ជាក់ទៀតថា នៅពេលល្ងាចខ្លួនបានទៅផ្ទះដើមបណ្តឹងមែន ក្នុងគោលបំណងទៅខ្ចីលុយអោយមិត្តភក្តិ តែទៅមិនជួបដល់ពេលយប់ទៀត ខ្លួនគាត់មិនបានទៅទៀតដែរ ។ ចំពោះការចាប់បីក្មេងស្រីទៅបន្ទប់ទឹកនោះ គឺខ្លួនមិនបានប្រព្រឹត្តឡើយ ។

-តាមចម្លើយរបស់ឈ្មោះ ខ ខទ ជាជនរងគ្រោះឆ្លើយថា អ្នកដែលចាប់បីខ្លួន និង ស្រាតខោវែងខ្លួន ព្រមទាំងពោបលើខ្លួន គឺពិតជាឈ្មោះ ចេ បចេ ដែលខ្លួនស្គាល់ច្បាស់តាមរយៈខែភ្លឺ និង ធ្លាប់ស្គាល់ដែលគាត់រស់នៅក្នុងភូមិជាមួយគ្នាកន្លងមក ។ ចម្លើយកុមារីជាចម្លើយពិត ព្រោះក្មេងនិយាយពិត និយាយត្រង់ មិនភូតភរកុហកនោះទេ ។ ចម្លើយនេះអាចមានមូលដ្ឋានគួរអោយតុលាការយកជាការបាន ។

-តាមការអះអាងរបស់ឈ្មោះ ចេ សច និងឈ្មោះ ម ជះ ដែលជាដើមបណ្តឹង និង ជាឪពុកម្តាយជនរងគ្រោះ នៅយប់កើតហេតុ ខ្លួនកំពុងតែសំរាន្តស្រាប់តែឮកូនស្រីយំ ក៏ផ្អើលនោរឡោទាំងយប់ ហើយបានពិនិត្យមើលប្រដាប់ភេទ ពុំមានអ្វីគួរអោយចាប់អារម្មណ៍ នឹងបានតាមរកឈ្មោះ ចេ បចេ ទាំងយប់នោះដែរ តែដល់ពេលជួបឈ្មោះ ហូះ ឈ្មោះនេះ បែបដឹងខ្លួន ក៏បើកម្ចងហើយរុញច្រាន ម ជះ ក៏គេចខ្លួនទាំងយប់នោះទៅ ។ ចំណុចនេះហើយ

ទំព័រ០២

ដែលធ្វើអោយសង្ស័យលើឈ្មោះ **ម្ខរ** បើខ្លួនគាត់មិនបានប្រព្រឹត្តអ្វីទេនោះ រឿងអីចាំបើកមុងហើយរុញច្រាន **ម ជ** ក្នុងលក្ខណៈភិតភ័យ ដោយមិនបានសួរហេតុផលអ្វីនោះទេ ។

-ការឆ្លើយប្រកែករបស់ជនជាប់ចោទនោះ គឺមិនសមហេតុផល ព្រោះជនរងគ្រោះគេស្គាល់មុខច្បាស់ និង សំលេង ថែមពោបពីលើ និង ងើបដើរចេញ ហើយដើរសំដៅរបងក៏ហក់ចុះពីលើរបងសំដៅទៅផ្ទះដែលគាត់ស្នាក់នៅ ។

-នៅទីនោះគ្មាននរណាឈ្មោះ **ឋ មឋ** ដែរជនរងគ្រោះមានអាយុ ០៨ឆ្នាំជាកូនសិស្ស គេស្គាល់ឈ្មោះ **ម្ខរ** នេះច្បាស់លាស់ ព្រោះពេលថ្ងៃល្ងាចឈ្មោះ **ម្ខរ** នេះមករកម្តាយគេម្តងរួចទៅហើយ ដែលមិនបានជួបម្តាយគេ គឺជួប តែ **ឩ ឩទ** ដែលជាហេតុធ្វើអោយឈ្មោះ **ឩ ឩទ** គាត់ស្គាល់មុខមាត់ឈ្មោះ **ម្ខរ** នេះពិតប្រាកដ ។

-ការឆ្លើយប្រកែកនេះ ជនជាប់ចោទគឺនឹកស្មានថា គ្មានសាក្សី គ្មានភស្តុតាងដែលចាប់ខ្លួននេះបានទេ ពុំមានទោសឡើយ ដូច្នេះឈ្មោះនេះ ចេះតែឆ្លើយប្រកែកទៅ ដើម្បីគេចផុតពីទណ្ឌកម្មតែប៉ុណ្ណោះ ។

-នៅពេលជនល្មើសបានជិះម៉ូតូឌុបសំដៅទៅឃ្លាំងលើ ដើម្បីរករថយន្តជិះបន្តទៅវាលរេញ ក្នុងគោលបំណង គេចខ្លួន តែដល់ចំណតឃ្លាំងលើឈ្មោះនេះហក់ចុះពីលើម៉ូតូរត់ឡើងឡានតាក់ស៊ី ព្រោះដឹងថាក្រុមគ្រួសារជនរងគ្រោះ ដេញតាមហើយ ។

-ការប្រព្រឹត្តរបស់ជនជាប់ចោទ គឺធ្វើទៅលើអនីតិជនដែលមានអាយុ ០៨ឆ្នាំប៉ុណ្ណោះ ប៉ុន្តែការប្រព្រឹត្តរបស់ ជនជាប់ចោទមិនមានលក្ខណៈធ្ងន់ធ្ងរមិនបានស្ទាបអង្អែលកេរ្តិ៍ភេទ ឬ រំលោភអោយស៊ីជម្រៅ និង មិនបានស្រាតខោខ្លី នោះដែរ គ្រាន់តែស្រាតខោវែងកុមារី រួចពោបពីលើក៏យកដៃលូកចូលក្នុងខោរបស់គាត់ រួចងើបចេញពីជនរងគ្រោះ គឺ ដោយសារសំរេចបំណងរបស់គាត់ គឺចេញទឹកកាមដោយខ្លួនឯង ។

-ជនរងគ្រោះមិនមានគ្រោះថ្នាក់ទាំងរាងកាយទាំងអាយុជីវិតផងដែរ ។

-ការប្រព្រឹត្តរបស់ជនជាប់ចោទជាលើកដំបូង ជនជាប់ចោទ និង ក្រុមគ្រួសារជនរងគ្រោះជាមនុស្សរាប់អាន គ្នា ស្គាល់គ្នា ធ្លាប់ធ្វើការរួមជាមួយទៀតផង មនោសញ្ចេតនារវាងជនល្មើស និង ក្រុមគ្រួសារនៅតែល្អនឹងគ្នាដោយសារ យ៉ាងដូច្នេះហើយដើមបណ្តឹងមិនទាមទារសំណងជម្ងឺចិត្តអ្វីដែរ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ឋ មឋ** ពីបទរៀតរៀនដល់កេរ្តិ៍ខ្មាស់ ប្រព្រឹត្តនៅសង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ**

**សំរេច :**

**ផ្តន្ទាទោស :**

ឈ្មោះ **ឋ មឋ** ហៅ **ស៊ុន** អាយុ ២៨ឆ្នាំ ភេទប្រុស ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០២ឆ្នាំ ( ពីរឆ្នាំ) តែក្នុងនោះទោសគុកចំនួន ០៨ខែ ( ប្រាំបីខែ) និង ទោសព្យួរ ១៦ខែ មានរយៈពេលសាកល្បង ០៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៤ ។

ពីបទរៀតរៀនដល់កេរ្តិ៍ខ្មាស់ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ៤២ និងមាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

CamScanner

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទ ជនរងគ្រោះ ដើមបណ្ដឹងបើកផ្លូវប្ដឹងឧទ្ធរណ៍ ក្នុងកំឡុងច្បាប់ ។

**ក្រឡាបញ្ជី**

[redacted]

**ចៅក្រមជំនុំជំរះ**

[redacted]